**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត
## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## និងជាប្រធានកិត្តិយសនៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
## នាឱកាសទិវាជាតិទីក្រុងស្អាត ក្រោមប្រធានបទ «ទីក្រុងស្អាត៖ ទីក្រុងដែលមានវិធីម្ហូបអាហារស្អាត»
## ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០

*សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ!*
*បងប្អូនជនរួមជាតិទាំងអស់ជាទីមេត្រី!*

ខ្ញុំព្រះករុណា ខ្ញុំមានសេចក្តីរីករាយជាអនេកដែលបានចូលរួមអបអរសាទរជាមួយបងប្អូនជនរួមជាតិទាំងអស់ក្នុងឱកាសអបអរសាទរទិវាជាតិទីក្រុងស្អាតលើកទី៨ ឆ្នាំ២០២០ ក្រោមប្រធានបទ **«ទីក្រុងស្អាត៖ ទីក្រុងដែលមានវិធីម្ហូបអាហារស្អាត»** អមដោយពិធីបិទសន្និបាតបូកសរុបការងារក្រសួងទេសចរណ៍ ឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្ត ឆ្នាំ២០២០ យ៉ាងមហោឡារិក នាពេលនេះ។

បច្ចុប្បន្ន កម្ពុជាមានសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់ល្អបរិបូរណ៍ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរ ការអភិវឌ្ឍលើគ្រប់វិស័យ និងមានកំណើនសេដ្ឋកិច្ចខ្ពស់គួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ លើសពីនេះទៀត ក្នុងដំណើរឆ្ពោះទៅមុខ កម្ពុជាត្រូវបន្តថែរក្សា **"សន្តិភាពឱ្យមានវត្តមានជាអចិន្ត្រៃយ៍"** និងត្រូវបន្តខិតខំប្រឹងប្រែងខ្លាំងក្លាបន្ថែមទៀត ដើម្បីទទួលបាននូវភាពរីកចម្រើនសម្រេចបានតាមបំណងប្រាថ្នារបស់ខ្លួន សំដៅបន្តកែលម្អជីវភាពនិងការរស់នៅរបស់ប្រជាជន និងការរួមចំណែកថែរក្សាភពផែនដីរបស់យើងសម្រាប់កូនចៅជំនាន់ក្រោយៗទៀត។ ក្នុងនោះ កម្ពុជាត្រូវបន្តយកចិត្តទុកដាក់ខ្ពស់លើការងារសំខាន់ៗជាអាទិ៍៖ **១- ការបន្តកាត់បន្ថយភាពក្រីក្រ ២- ការលើកកម្ពស់សុខភាពនិងសុខុមាលភាពប្រជាជន ៣- ការគិតគូរពីចីរភាពនៅតាមបណ្តាទីក្រុង ៤- ការឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុ ៥-កិច្ចការពារនិងអភិរក្សធនធានធម្មជាតិ។**

ក្នុងស្មារតីឆ្លើយតបទៅនឹងការវិវត្តន៍និងនិន្នាការអភិវឌ្ឍន៍ថ្មីៗនេះ កម្ពុជាត្រូវបន្តយកចិត្តទុកដាក់លើការដាក់ចេញនិងអនុវត្តនូវគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនានា ដោយឈរលើមូលដ្ឋានសំខាន់ពីរ ដែលត្រូវគិតគូរស្របពេលគ្នាគឺ៖ **ការបង្កើនឧត្តមភាពប្រកួតប្រជែង និងការធានានិរន្តរភាពនៃការអភិវឌ្ឍ។** ឈរលើមូលដ្ឋាននេះ កម្ពុជាក៏បានដាក់ចេញនូវយុទ្ធនាការ **«ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ**

**បដិញ្ញាកិច្ចល្អ** ដែលជាយុទ្ធសាស្ត្រដ៏សមស្របក្នុងការចូលរួមអភិវឌ្ឍវិស័យទេសចរណ៍ជាមាសបៃតង និងនាំកម្ពុជាឆ្ពោះទៅរកភាពស្អាត បៃតង និងប្រកបដោយសុវត្ថិភាពខ្ពស់។

ឆ្នាំនេះ ជាឆ្នាំទី៨ ដែលយើងប្រារព្ធធ្វើទិវាជាតិទីក្រុងស្អាត ក្រោមប្រធានបទ **«ទីក្រុងស្អាត៖ ទីក្រុងដែលមានវិថីម្ហូបអាហារស្អាត»**។ តាមរយៈប្រធានបទនេះគឺ ឆ្លុះបញ្ចាំងយ៉ាងច្បាស់ថាវិថីម្ហូបអាហារគឺជាផលិតផលទេសចរណ៍ដ៏ទាក់ទាញមួយសម្រាប់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ ដែលអាចផ្តល់នូវបទពិសោធន៍និងការចងចាំសម្រាប់ភ្ញៀវទេសចរដែលជាទូទៅភ្ញៀវទេសចរតែងប្រាថ្នាចង់ដើរកម្សាន្តនិងទទួលទានម្ហូបអាហារដែលប្រកបដោយអនាម័យនិងជឿទុកចិត្ត ខណៈដែលវិថីម្ហូបអាហារក៏ជាផ្នែកមួយនៃទេសចរណ៍ម្ហូបអាហារដែលផ្សារភ្ជាប់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានទៅនឹងជីវភាពប្រជាជន វប្បធម៌ និងទំនៀមទម្លាប់ ព្រមទាំងជួយជំរុញអាជីវកម្មខ្នាតតូចបែបគ្រួសារឱ្យរីកលូតលាស់បានយ៉ាងមានប្រសិទ្ធភាព។ ជាការពិតវិស័យទេសចរណ៍និងម្ហូបអាហារមានទំនាក់ទំនងជាសារវ័ន្តពីរគឺ៖ **ម្ហូបអាហារជាផលិតផលទេសចរណ៍ ឬសេវាកម្មទេសចរណ៍** (Gastronomy Tourism Product) និង**ម្ហូបអាហារជាចំណែកទីផ្សារទេសចរណ៍** (Market Segment) ដ៏ទាក់ទាញ។ ម្ហូបអាហារជាទូតនាំសារអំពីវប្បធម៌ អត្តសញ្ញាណ ការរស់នៅក្នុងតំបន់ទៅភ្ញៀវទេសចរជាតិនិងអន្តរជាតិ និងបានបង្កើតភាពចងចាំដល់ទេសចរអំពីគោលដៅដែលបានទស្សនា។ ត្រង់ចំនុចនេះយើងចាំបាច់ត្រូវកែច្នៃ ចងក្រងខ្លឹមសារបកស្រាយ បង្ហាញ និងលើកគុណតម្លៃអំពីម្ហូបអាហារ ដែលសម្បត្តិបេតិកភណ្ឌវប្បធម៌ទាំងនេះបម្រើឱ្យសេវាកម្មទេសចរណ៍ផងនិងចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋានផងដែរ ពីព្រោះចំណាយជាមធ្យមនៃភ្ញៀវទេសចរគឺមានប្រមាណ២៥% លើចំណីអាហារដែលនេះគឺជាការផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចយ៉ាងច្រើន។ ការបង្កើតថ្មីម្ហូបអាហារក៏រួមចំណែក**បង្កើតអត្តសញ្ញាណនៅតាមគោលដៅទេសចរណ៍ដែលគាំទ្រដល់ការផ្សព្វផ្សាយទេសចរណ៍**។ ទន្ទឹមនឹងនោះ **"ទេសចរណ៍ម្ហូបអាហារ"** កំពុងតែទទួលបានការពេញនិយមពីភ្ញៀវទេសចរ ពីព្រោះថា**ភ្ញៀវទេសចរនឹងធ្វើដំណើរទៅតំបន់ណាមួយ គឺដើម្បីភ្លក់រសជាតិម្ហូបអាហារនៅតំបន់គោលដៅនេះ**។ អ្នកធ្វើដំណើរម្ហូបអាហារ (Gastronomy Traveler) ទាំងនេះភាគច្រើនជាទេសចរក្នុងស្រុកឬទេសចរអន្តរជាតិដែលធ្វើដំណើរច្រើនគោលដៅក្នុងប្រទេសមួយដើម្បីភ្លក់រសជាតិម្ហូបអាហារដែលជាការរួមចំណែកយ៉ាងខ្លាំងជំរុញចលនាទេសចរណ៍ផ្ទៃក្នុងនិងក៏ដូចជាចលនាទេសចរណ៍ក្នុងស្រុកផងដែរ។ ក្នុងន័យនេះ ការរៀបចំវិថីឱ្យមាន ម្ហូបអាហារនៅតាមទីក្រុងដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចទីក្រុង និងទេសចរណ៍ទីក្រុង ដែលចាំបាច់គ្រប់ក្រុង/ខណ្ឌទាំងអស់ ស្រុកទាំងអស់ត្រូវតែមានវិថីម្ហូបអាហារមួយយ៉ាងតិចដូចប្រធានបទ **"ទីក្រុងស្អាត៖ទីក្រុងមានវិថីម្ហូបអាហារស្អាត"**។

ខ្ញុំមានជំនឿជឿជាក់ថា ការរៀបចំឱ្យមានវិថីម្ហូបអាហារនៅតាមរាជធានី ខេត្ត មិនត្រឹមតែចូលរួមទាក់ទាញទេសចរជាតិ អន្តរជាតិ លើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងលើកតម្កើងប្រពៃណី បេតិកភណ្ឌជាតិប៉ុណ្ណោះទេ ថែមទាំងចូលរួមបង្កើត**ការងារបន្ថែមជំរុញសហគ្រិនភាពការបង្កើតថ្មីនិងភាពច្នៃប្រឌិត**ផងដែរ។ ច្បាស់ណាស់ថាវិជ្ជាជីវៈផ្នែកម្ហូបអាហារទាមទារទាំងធន្ធ: ចំណេះដឹង ជំនាញ ឥរិយាបថខ្ពស់ សិល្បៈ និងគំនិតច្នៃប្រឌិតដែលមិនអាចខ្វះបាន។ ការអភិវឌ្ឍវិស័យទេសចរណ៍ម្ហូបអាហារពិតជានាំមកនូវការរីកចម្រើនផ្នែកអាជីពក្នុងវិស័យទេសចរណ៍ ជាពិសេសចូលរួមទប់ស្កាត់ការចំណាកស្រុក និងបង្កើនស្មារតីស្រលាញ់ជាតិមាតុភូមិ។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមឱ្យស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិបន្តខិតខំរួមចំណែកលើកកម្ពស់ប្រពៃណី វប្បធម៌ និងបេតិកភណ្ឌម្ហូបអាហាររបស់ខ្លួន សំដៅចូលរួមជំរុញឱ្យមានភាព

សំបុរបែបនៃម្ហូបអាហារនិងត្រូវ "ក្រុង/ខណ្ឌមួយ ត្រូវមានវិថីម្ហូបអាហារមួយយ៉ាងតិច" "ស្រុកមួយត្រូវមាន**វិថីម្ហូបអាហារមួយយ៉ាងតិច**" ដើម្បីបម្រើដល់វិស័យទេសចរណ៍ដែលមកទស្សនាក្នុងទីក្រុងប្រកបដោយភាពពេញចិត្តនិងបទពិសោធន៍ល្អប្លែកៗស្របតាមយុទ្ធនាការផ្សព្វផ្សាយ "**កម្ពុជា៖ព្រះរាជាណាចក្រអច្ឆរិយៈ៖ ផ្តល់ភាពកក់ក្តៅ**"។ ខ្ញុំក៏សូមប្រកាសដាក់ឱ្យអនុវត្តស្តង់ដា "**វិថីម្ហូបលក់ម្ហូបអាហារកម្ពុជា-Food Street**" និងស្តង់ដា "**តូបលក់ម្ហូបអាហារតាមដងផ្លូវកម្ពុជា-Street Food**" ជាផ្លូវការ។

ខ្ញុំព្រះករុណា ខ្ញុំសង្ឃឹមនិងជឿជាក់យ៉ាងមុតមាំថា គ្រប់ភាគីពាក់ព័ន្ធទាំងអស់នឹងបន្តសហការចូលរួមគាំទ្រឧបត្ថម្ភ និងអនុវត្តរាល់យុទ្ធនាការនានាដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល ដើម្បីគាំទ្រដល់ចលនាប្រឡងប្រណាំង "**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ**" ដើម្បីកម្ពុជាជាគោលដៅទេសចរណ៍ "**ស្អាត និងបៃតង**" ស្របតាមយុទ្ធនាការផ្សព្វផ្សាយទេសចរណ៍ "**កម្ពុជា៖ព្រះរាជាណាចក្រអច្ឆរិយៈ៖ ផ្តល់ភាពកក់ក្តៅ**" និងសូមជូនពរឱ្យ**ទិវាជាតិទីក្រុងស្អាត** និង**ចលនាប្រឡងប្រណាំងទីក្រុងស្អាត**ប្រព្រឹត្តទៅប្រកបដោយជោគជ័យជានិច្ចនិរន្តរ៍។

ខ្ញុំក៏សូមយកឱកាសក្នុងពិធីអបអរសាទរទិវាជាតិទីក្រុងស្អាតឆ្នាំ២០២០នេះ សូមស្វាគមន៍ភ្ញៀវទេសចរអន្តរជាតិពីគ្រប់ទិសទីមកទស្សនាកម្សាន្តនៅព្រះរាជាណាចក្រកម្ពុជា ហើយសូមអំពាវនាវដល់ជនរួមជាតិឱ្យចូលរួមគាំទ្រសកម្មភាពទេសចរណ៍ និងចលនាទេសចរណ៍ក្នុងស្រុក ដោយអញ្ជើញធ្វើដំណើរកម្សាន្តទស្សនាតំបន់ទេសចរណ៍នានានៅទូទាំងប្រទេសដើម្បីរួមចំណែកជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ ជំរុញសកម្មភាពសេដ្ឋកិច្ចផ្ទៃក្នុងផង និងបង្កើនមនសិការនិងស្មារតីស្រលាញ់ជាតិមាតុភូមិ សាមគ្គីភាព មិត្តភាព និងចែករំលែកផលប្រយោជន៍ដោយសមធម៌ជូនប្រជាជននៅមូលដ្ឋាន។

ជាទីបញ្ចប់ ក្នុងឱកាសអបអរសាទរ **ទិវាជាតិទីក្រុងស្អាតលើកទី៨ ឆ្នាំ២០២០ អមដោយពិធីបិទសន្និបាតបូកសរុបការងារក្រសួងទេសចរណ៍ ឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្ត ឆ្នាំ២០២០**នេះ ខ្ញុំព្រះករុណាខ្ញុំសូមថ្វាយព្រះពរនិងប្រគេនពរជូនសម្តេចព្រះសង្ឃរាជ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនពរបងប្អូនជនរួមជាតិទាំងអស់ សមប្រកបដោយពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ ចន្ទ ១១ រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២០

**ហ៊ុន សែន**